# ក្រុមគ្រូពេទ្យទន្តសាស្ត្រ

**Dental technician/mechanic** (អ្នកបច្ចេកទេសធ្វើធ្មេញ រឺ អ្នក labo) គឺជាសមាជិកដ៏សំខាន់នៃក្រុមគ្រូពេទ្យទន្តសាស្ត្រដែលជាអ្នកមានជំនាញក្នុងការ រចនា សាងសង់ ជួសជុល និង កែតំរូវឧបករណ៍ធ្មេញមួយចំនួនធំ។ ពួកគេធ្វើការពីការណែនាំជាលាយលក្ខណ៍អក្សរ និង ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយទន្តពេទ្យ។

អ្នក labo ទទួលយកដ្យាក្រាបប្លង់ជាលក្ខណៈ 2D រួមផ្សំនិងការណែនាំជាលាយលក្ខណ៍អក្សរ ហើយបង្កើតជាផលិតផលក្នុងលក្ខណៈជា 3D។

- ស្ដាបនាធ្មេញធម្មជាតិ (crowns, inlays/onlays, veneers);
- ដាក់ជំនួសធ្មេញ (bridges, ធ្មេញស្អិតទាំងស្រុង រឺ ដោយផ្នែក, prosthesis សំរាប់ implant);
- ដាក់ជំនួសរចនាសម្ពន្ធ័រឹងនិងទន់របស់មាត់ (បង្កើតសោភ័ណភាពឡើងវិញ)
- រំកិល រក្សា និង ការពារធ្មេញ (វិស័យពត់តំរង់ធ្មេញ: ប្រដាប់ការពារមាត់ ឧបករណ៍អបធ្មេញ ឧបករណ៍យកពុម្ពធ្មេញ ឧបករណ៍សំរាប់ទប់ជាលិកាទន់)
- តំរង់ទីតាំងឆ្អឹងថ្គាម (វះកាត់ពត់តំរង់ធ្មេញ: TMJ, sleep apnoea -ល-)។

**Dental therapist** គឺជាអ្នកអាជីពថែទាំសុខភាពដែលផ្ដល់សេវាកម្មស្ដាបនា និង ការពារធ្មេញ សំរាប់កុមារ និង មនុស្សចាស់។ ដូចអ្នក labo ដែរ, dental therapist តំរូវអោយធ្វើការជាមួយទន្តពេទ្យដើម្បីសំរេចចិត្តធ្វើការព្យាបាលសមស្របណាមួយសំរាប់អ្នកជំងឺណាម្នាក់។ នៅពេល គំរោងព្យាបាលបានឯកភាពគ្នាជាមួយទន្តពេទ្យ នោះ dental therapist នឹងធ្វើការព្យាបាលដោយបិតប៉ះធ្មេញ និង ដកធ្មេញទឹកដោះ។ ពួកគេមិនទទួលព្យាបាលរន្ធឫសធ្មេញ ការព្យាបាលបិតប៉ះធ្មេញដែលមានលក្ខណៈធ្ងន់ធ្ងរ ការវះកាត់តូចតាច រឺ ការធ្វើធ្មេញស្អិតជាបណ្ដោះអាសន្នឡើយ។

**Dental hygienist** គឺជាអ្នកអាជីពថែទាំសុខភាព ដែលជាអ្នកផ្ដល់សេវាកម្មការពារមានជំនាញខ្ពស់ទៅលើមនុស្សគ្រប់អាយុដោយមិនមានការកាត់រឺដកធ្មេញឡើយ។ ដូចអ្នក labo ដែរ ពួកគេធ្វើការដោយមានការពិភាក្សាជាមួយទន្តពេទ្យដើម្បីកំណត់ការព្យាបាលរារាំងទុកមុនដ៏ប្រសើរបំផុតសំរាប់អ្នកជំងឺម្នាក់ៗ ប៉ុន្តែពួកគេធ្វើការដោយឯករាជ្យ ក្នុងការផ្ដល់សេវាកម្មទន្តសាស្ត្ររបស់ពួកគេ។ ជាទូទៅ ពួកគេធ្វើការព្យាបាលជាមួយអ្នកជំងឺដែលមានជំងឺជាលិកាជុំវិញធ្មេញធ្ងន់ធ្ងរ រឺ កំពុងវិវត្តន៍ ហើយពួកគេទទួលធ្វើការកោសសំអាត និង សំអាតធ្មេញដើម្បីជួយអ្នកជំងឺថែទាំធ្មេញរបស់ពួកគេ។

**Specialist Dentists (ទន្តពេទ្យឯកទេស)**គឺជាទន្តពេទ្យដែលបានសិក្សា រឺ បានទទួលសញ្ញាប័ត្របន្ថែមទៀតដើម្បីផ្ដល់នូវការថែទាំជាពិសេសថ្នាក់ខ្ពស់នៅក្នុងផ្នែកមួយនៃវិស័យទន្តសាស្ត្រ។ ជាទូទៅ ពួកគេត្រូវបានគេហៅថា អ្នកផ្ដល់ប្រឹក្សា នៅពេលពួកគេធ្វើការបង្ហាត់បង្រៀន ជំនាញ និង ចំណេះដឹងខ្ពស់ៗ នៅតាមសាកលវិទ្យាល័យ រឺ មហាវិទ្យាល័យនានា។

**Orthodontists (អ្នកឯកទេសពត់តំរង់ធ្មេញ):** មានឯកទេសលើការវិវត្តន៍ដំណុះធ្មេញកុមារ និង ធ្វើគំរោងព្យាបាល ដើម្បីកែតំរូវកំណាំធ្មេញខុសប្រក្រតីណាមួយ។ ពួកគេក៏នឹងព្យាបាលមនុស្សពេញវ័យដែលត្រូវការតំរង់ធ្មេញពួកគេអោយបានត្រឹមត្រូវ។

**Oral Surgeons (អ្នកវះកាត់មាត់):** មានឯកទេសក្នុងការវះកាត់នៅក្នុងមាត់ដែលអាចនឹងរួមមានការដកធ្មេញដុះមិនចេញ រឺធ្មេញកប់ ការកាត់យកជាលិកាដើម្បីយកទៅពិនិត្យប្រភេទជំងឺ និង ការវះកាត់យកជំងឺបង្ករោគផ្សេងៗចេញ។

ក៏មានផងដែរនូវទន្តពេទ្យឯកទេសផ្សេងៗ ដូចជា Periodontologists (អ្នកឯកទេសជំងឺជាលិកាជុំវិញធ្មេញ)-- ព្យាបាលជាលិកាជុំវិញធ្មេញ, Prosthodontists (អ្នកឯកទេសដាក់ធ្មេញ)-- ធ្មេញស្ថិតនានា, Endodontists (អ្នកឯកទេសព្យាបាលរន្ធឫស)-- ព្យាបាលរន្ធឫស, Paedodontists (អ្នកឯកទេសខាងកុមារ) -- យកចិត្តទុកដាក់ព្យាបាលកុមារ, Oral medicine specialists, អ្នកឯកទេសបិតប៉ះធ្មេញ, អ្នកឯកទេសដាំបង្គោលក្នុងឆ្អឹងថ្គាម។

**ការទំនុកបំរុងផ្នែករដ្ឋបាល**

**គ្លីនិច រឺ អ្នកគ្រប់គ្រងអនុវត្តន៏** នឹងទទួលខុសត្រូវចំពោះការចាត់ចែងរបស់គ្លីនិចដើម្បីធានាថាមានដំណើរការនានានៅនឹងកន្លែងសំរាប់ធ្វើការដោយមានសុវត្ថិភាពរបស់គ្លីនិច ក៏ដូចជាការបើកប្រាក់បៀវត្សរ៏អោយទៅបុគ្គលិក និង ការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្លីនិច។ **អ្នកទទួលភ្ញៀវ** នឹងទទួលខុសត្រូវលើការចាត់ចែងការណាត់ជួបអ្នកជំងឺ ការហៅនិងបង់ប្រាក់ និង ការគ្រប់គ្រងកំណត់ត្រារបស់អ្នកជំងឺ។